# មេរៀនទី៧៖ សាតាំងល្បួងព្រះយេស៊ូវ

លូកា ៤៖១-១៣

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/FDQnfAOOHmM

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/G3lJWEOPwFo

**គោលបំណង៖** ព្រះយេស៊ូវមានអំណាចឈ្នះលើសេចក្តីល្បួង

**ខគម្ពីរចងចាំ៖ ម៉ាថាយ ៤៖៧** *ព្រះយេស៊ូវមានព្រះបន្ទូលទៅវាថា មានសេចក្តីចែងទុកដូច្នេះទៀត «កុំឲ្យឯងល្បួងព្រះអម្ចាស់ ជាព្រះនៃឯងឡើយ»។*

**ចំរៀង** ( *យូធូបលីង* )៖

១. សរសើរព្រះយេស៊ូវ https://youtu.be/uA448Ncse8Q

២. ព្រះអម្ចាស់ទ្រង់ស្ថិតស្ថេរ https://youtu.be/suW4J1Wbxa4

៣. ក្នុងព្រះនាមព្រះយេស៊ូវ https://youtu.be/0b41QksexPE

**១.អធិស្ឋាន**

**២. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

**៣. ល្បែងកំសាន្ត «តើអ្នកមានបាបឬទេ?»**

សូមឲ្យកុមារទាំងអស់ក្រោកឈរឡើង។ ពួកគេអាចអង្គុយចុះបាន បើសិនជាពួកគេបានឆ្លើយ "បាទ/ចា៎" នៅពេលគ្រូសួរសំណួរ

ក. តើប្អូនធ្លាប់វាយនរណាម្នាក់ទេដែរឬទេ? *(បើធ្លាប់ សូមអង្គុយចុះ)*

ខ. តើប្អូនធ្លាប់និយាយកុហក់ដែរឬទេ? *(បើធ្លាប់ សូមអង្គុយចុះ)*

គ. តើប្អូនធ្លាប់ធ្វើអាក្រក់ដាក់នរណាម្នាក់ដែរឬទេ? *(បើធ្លាប់ សូមអង្គុយចុះ)*

ឃ. តើប្អូនធ្លាប់មិនស្តាប់បង្គាប់ឪពុកម្តាយរបស់ប្អូនដែរឬទេ? *(បើធ្លាប់ សូមអង្គុយចុះ)*

សូមពន្យល់កុមារថា តើប្អូនឃើញទេ គឺគ្មាននរណាម្នាក់នៅឈរទៀតទេ ពីព្រោះថាពួកយើងមិនគ្រប់លក្ខណ៍នោះឡើយ។ ប៉ុន្តែអ្វី ដែលជាដំណឹងល្អនោះ គឺថាព្រះអង្គទ្រង់ជ្រាបថាយើងមិនគ្រប់លក្ខណ៍ទេ! ដូច្នេះហើយទើបទ្រង់បានបញ្ជូនព្រះយេស៊ូវមកសំរាប់យើងរាល់គ្នា! ព្រះយេស៊ូវមិនមានបាបទេ ប៉ុន្តែព្រះអង្គបានសុគតជំនួសយើង ដូច្នេះយើងនឹងមានជីវិតអស់កល្ប។

ង. តើសេចក្តីល្បួងដែលប្អូនជួបប្រទះសព្វថ្ងៃនេះមានអ្វីខ្លះ? *(លេងទូរស័ព្ទ គប់ង់ស៊ីលុយ លេងឈូស មើលទូរទស្សន៍)*

ច. តើប្អូនៗយកឈ្នះសេចក្តីល្បួងទាំងនោះដោយរបៀបណា? *(អធិស្ឋាន អានគម្ពីរ ដាក់វិន័យឲ្យខ្លួនឯង)*

**៤. ការណែនាំមេរៀន « សុភាពចាញ់ល្បួង »**

មានប្តីប្រពន្ធជាកសិករមួយគូ ដែលមានប្រពន្ធឈ្មោះ សុភាព។ ថ្ងៃមួយនៅពេលបុរសជាប្តីបានចេញទៅធ្វើការនៅខាងក្រៅ សុភាពបានដុតមាន់១យ៉ាងឈ្ងុយឆ្ងាញ់ដើម្បីធ្វើម្ហូបញ៉ាំជុំគ្នាជាមួយប្តីរបស់គាត់។

បន្ទាប់ពីបានរៀបចំម្ហូបដាក់ចានរួចហើយ គាត់ក៏អង្គុយរង់ចាំប្តីត្រឡប់មកវិញនៅក្បែរចានម្ហូបនោះ។ តែដោយសារតែរង់ចាំប្តីយូរពេក ហើយមើលទៅមាន់ដែលកំពុងជះក្លិន ឈ្ងុយទៅៗផងនោះ ធ្វើឲ្យគាត់ទ្រាំមិនបានក៏លូកដៃកាច់ស្លាបមួយចំហៀងញ៉ាំបណ្តើរទាំងលិទ្ធដៃបណ្តើរ ហើយក៏លូកដៃទៅបេះ ភ្លៅ, ស្លាប, ទ្រូងមាន់រហូតញ៉ាំមាន់ទាំងមូលអស់រលីងចោលប្តីទៅ។ ដោយសារតែក្លិនឈ្ងុយ និងការ ស្រេកឃ្លាន ធ្វើឲ្យសុភាពបានញ៉ាំមាន់អស់តែម្នាក់ឯងតែម្តង។ ។ ដូចគ្នាដែរ តាមរយៈភ្នែកនិងដួងចិត្តស្រេកឃ្លានរបស់យើងបានធ្វើ ឲ្យយើងធ្លាក់ទៅក្នុងសេចក្តីល្បួងជាច្រើន។ ថ្ងៃនេះយើងនិងនាំប្អូនៗទៅមើលរឿងនៅក្នុងព្រះគម្ពីរ អំពីរបៀបដែលព្រះយេស៊ូវគ្រីស្ទបានយកឈ្នះលើសេចក្តីល្បួង។ ថាតើទ្រង់យកឈ្នះ សេចក្តីល្បួងដោយរបៀបណា?

## ៥. រឿងនៅក្នុងព្រះគម្ពីរ

សេចក្តីល្បួងខ្លះអាចធ្វើឲ្យយើងពិបាកនឹងយកឈ្នះលើវាបានណាស់។ ប៉ុន្តែព្រះយេស៊ូវបានយកឈ្នះលើសេចក្តីល្បួងបានយ៉ាងអស្ចារ្យបំផុត។ មានពេលមួយដែលព្រះយេស៊ូវបានចំណាយពេលអស់ ៤០ថ្ងៃ ៤០យប់ នៅក្នុងទីរហោស្ថានដោយមិនបានសោយអ្វីទាំងអស់។ ដែលនោះហៅថាការតមអាហារ ជាការមិនញ៉ាំអ្វីទាំងអស់ នៅក្នុងរយៈពេលកំណត់ជាក់លាក់ណាមួយ ដូច្នេះអ្នកអាចអធិស្ឋានទៅរកព្រះបាន។ រយៈពេល៤០ថ្ងៃដោយមិនបានញ៉ាំអ្វីសោះគឺយូរណាស់! ព្រះយេស៊ូវអស់កម្លាំង ហើយទ្រង់ឃ្លានក៏ឃ្លានដែរ។ នោះហើយជាពេលដែលសាតាំងបង្ហាញខ្លួន ហើយចាប់ផ្តើមល្បួងព្រះអង្គ។ សាតាំងដឹងយ៉ាងច្បាស់ថា ព្រះយេស៊ូវនឹងមិនធ្វើអ្វីដែលជាការអាក្រក់នោះទេ ព្រះអង្គនឹងមិនលួច មិនសំលាប់ឬ មិនបំផ្លាញអ្វីទាំងអស់។ ដូច្នេះសាតាំងមានផែនការល្អជាងនេះ ដោយបានយកអាហារមកល្បួងព្រះយេស៊ូវវិញ។ វាបាននិយាយថា **លូកា ៤៖៣** "បើអ្នកជាព្រះរាជបុត្រានៃព្រះមែន ចូរបង្គាប់ឲ្យថ្មនេះត្រឡប់ជានំបុ័ងទៅ" សាតាំងបាន ព្យាយាមឲ្យព្រះយេស៊ូវប្រើអំណាចរបស់ទ្រង់ទៅក្នុងផ្លូវខុស។ ព្រះយេស៊ូវជ្រាបថាវាជារឿង មិនត្រឹមត្រូវ ដូច្នេះទ្រង់បាន បានឆ្លើយត្រលប់ទៅវិញថា "មនុស្សមិនមែនរស់ ដោយសារតែនំបុ័ងប៉ុណ្ណោះ ទេ" ។ ចំពោះព្រះយេស៊ូវការស្តាប់បង្គាប់ព្រះគឺសំខាន់ជាងការដែលស្វែងរកអាហារខាងឯសាច់ឈាម។ សាតាំងមិនបានបញ្ចប់ត្រឹមនេះទេ វាបាននាំព្រះយេស៊ូវទៅលើកំពូលភ្នំយ៉ាងខ្ពស់ ហើយបង្ហាញព្រះអង្គឲ្យឃើញពីនគរទាំងអស់នៅលោកីយ៍។ វាបាននិយាយថា **លូកា ៤៖៧** "ដូច្នេះ បើអ្នកក្រាបថ្វាយបង្គំខ្ញុំ នោះទាំងអស់នឹង បានជារបស់អ្នក" ព្រះយេស៊ូវដឹងថាទ្រង់មិនគួរថ្វាយបង្គំអ្នកណាទាំងអស់ក្រៅពីព្រះ។ ព្រះអង្គប្រាប់ទៅ សាតាំងនៅក្នុង **លូកា ៤៖៨** ថា "ត្រូវឲ្យឯងថ្វាយបង្គំដល់ព្រះអម្ចាស់ ជាព្រះនៃឯង ហើយត្រូវគោរពដល់ទ្រង់តែ១ព្រះអង្គប៉ុណ្ណោះ" ។

ឃើញដូច្នេះសាតាំងបានព្យាយាមល្បួងព្រះយេស៊ូវតាមវិធីផ្សេងទៀត ដោយវាបាននាំព្រះយេស៊ូវដាក់ នៅលើកំពូលព្រះវិហារ រួចទូលថា "បើអ្នកជាព្រះរាជបុត្រានៃព្រះមែន ចូរទំលាក់ខ្លួនពីនេះទៅក្រោមចុះ ហើយ រង់ចាំមើលថាទេវតារបស់ព្រះនឹងមកសង្គ្រោះអ្នក" តែព្រះយេស៊ូវដឹងថាវាមិនគួរល្បងលព្រះដោយវិធីនេះ ទេ រួចទ្រង់បានមានព្រះបន្ទូលតបទៅសាតាំងថា ព្រះជាម្ចាស់មានបន្ទូលនៅក្នុង **លូកា ៤៖១២** "កុំឲ្យឯង ល្បងព្រះអម្ចាស់ជាព្រះនៃឯងឡើយ"

ចុងក្រោយសាតាំងបានចុះចាញ់ ហើយក៏ថយចេញទៅ ដោយដឹងថាវាមិនអាចល្បួងព្រះយេស៊ូវអោយប្រព្រឹត្តអំពើបាបបានឡើយ។

ព្រះយេស៊ូវយកឈ្នះលើសេចក្តីល្បួងជាច្រើនបែបនេះពេញក្នុងមួយជីវិតរបស់ទ្រង់។ ភាពខុសគ្នារវាងព្រះយេស៊ូវ នឹងយើងដែលជាមនុស្សគឺព្រះអង្គមិនដែលធ្វើបាបទេ។ រឿងនេះប្រហែលជាធ្វើឲ្យយើងភ្ញាក់ផ្អើល ប៉ុន្តែបើយើងក្រឡេកមើលកាន់តែជ្រៅទៅ យើងឃើញថាព្រះយេស៊ូវបានជួបការលំបាកច្រើនជាងខ្ញុំ និងប្អូនទៅទៀត! សូមឲ្យយើងបានគិតជាមួយគ្នាថាៈ ព្រះយេស៊ូវមានអំណាចគ្រប់យ៉ាងដើម្បីធ្វើអ្វីដែលទ្រង់ចង់ធ្វើ! ប៉ុន្តែអ្នកគ្រូ និងប្អូនទាំងអស់គ្នាមិនអាចធ្វើបានទេ។ ហើយព្រះអង្គក៏មិនដែលជ្រើសរើសយកវិធីណាដែលងាយស្រួលនោះដែរ!ទ្រង់មានអំណាចហើយទ្រង់មិនដែលប្រើនូវអំណាចទាំងនោះ ដើម្បីបម្រើផលប្រយោជន៍របស់ទ្រង់ឡើយ។ ព្រះអង្គក៏ចេះឃ្លាន ហើយទ្រង់ក៏អាចធ្វើឲ្យថ្មក្លាយទៅជានំប៉័ងបានដែរ។ ទ្រង់បានស៊ូទ្រាំ ហើយតយុទ្ធជាមួយនឹងសេចក្តីល្បួងទាំងនោះ។ ព្រះអង្គជ្រើសរើសយកការ មិនប្រព្រឹត្តនូវអំពើបាប ពីព្រោះទ្រង់ស្រលាញ់ព្រះជាម្ចាស់ ហើយក៏ស្រលាញ់យើង។

## ៦. សំនួរពិភាក្សា

១. តើអ្វីជាសេចក្តីល្បួងដំបូងបំផុតចំពោះព្រះយេស៊ូវ? ( *ធ្វើឲ្យថ្មក្លាយទៅជានំប៉័ង ហើយញ៉ាំវា*)
២. តើអ្វីជាសេចក្តីល្បួងទី២ចំពោះព្រះយេស៊ូវ? ( *ថ្វាយបង្គំសាតាំង ហើយសាតាំងសន្យាឲ្យលោកីយ៍ទៅព្រះអង្គ*)
៣. តើអ្វីជាសេចក្តីល្បួងទី៣ចំពោះព្រះយេស៊ូវ? ( *លោតពីលើទីខ្ពស់ ហើយល្បងលព្រះមើលថាតើទ្រង់នឹងបង្គាប់ពួកទេវតាទ្រង់ មកជួយទ្រង់ដែរឬអត់*)
៤. តើព្រះយេស៊ូវយកឈ្នះសេចក្តីល្បួងដោយរបៀបណា?( *ដោយសារព្រះបន្ទូល*)
៥. សព្វថ្ងៃនេះតើអ្វីជាសេចក្តីល្បួងតាមរយៈភ្នែក និងចិត្តរបស់ប្អូន? ( *តាមរយៈការមើលរឿងមិនល្អនៅតាមបណ្តាញសង្គម ហ្វេសប៊ុក, តិកតុក, ទូរស្សន៍, លួចគេ, បោកប្រាស់មិត្តភក្តិ...*)

## ៧. ល្បែងកំសាន្ត « ព្រះយេស៊ូវអាចសំអាតយើងឲ្យស្អាតបាន »






សំភារៈដែលត្រូវការៈ កែវថ្លា២ ទឹក ដី និង ចាន១

ក. យកកែវទឹកទាំង២លើកបង្ហាញកុមារ ហើយពន្យល់ថា កែវទឹកនៅខាងស្តាំគឺតំណាងឲ្យព្រះយេស៊ូវ ហើយកែវទឹកនៅខាងឆ្វេងគឺតំណាងឲ្យយើងជាមនុស្ស។



ខ. យើងបានធ្វើបាបគ្រប់ពេល វាដូចជាយើងបន្ថែមដីមកក្នុងជីវិតរបស់យើងយ៉ាងដូច្នោះ ( ដាក់ដីចូលក្នុងកែវខាងឆ្វេងដែលតំណាងឲ្យយើង )



គ. ចាក់ទឹកកខ្វក់ដែលមានលាយដីនោះទៅក្នុងចាន រួចបង្ហាញដីលាយភក់នោះទៅកុមារ ហើយពន្យល់គេថា ពេលដែលយើងធ្វើបាប ធ្វើឲ្យជីវិតនិងចិត្តរបស់យើងក្លាយជាមិនស្អាត ហើយពួកគេក៏ក្លាយដូចជាភក់នេះ។

ឃ. ប៉ុន្តែព្រះយេស៊ូវមិនបានធ្វើបាបទេ! ព្រះអង្គបរិសុទ្ធដូចជាកែវទឹកដែលតំណាងឲ្យ ទ្រង់អ៊ីចឹង។ ព្រះអង្គបានរស់នៅក្នុងជីវិតដែលគ្មានអំពើបាប ដូច្នេះហើយធ្វើឲ្យយើងដែលជាអ្នកដើរ តាមទ្រង់មិនមានអារម្មណ៍ថាខ្លួនយើងមិនស្អាតនោះទេ។ ដោយសារព្រះអង្គមិនបានធ្វើបាប ដូច្នេះហើយបានជាទ្រង់ អាចទទួលយកនូវអំពើបាបទាំងអស់របស់យើងទៅដាក់លើអង្គទ្រង់ ហើយទ្រង់បានជួយយើងឲ្យបានស្អាត!



ង. សូមយកទឹកដែលតំណាងឲ្យព្រះយេស៊ូវ ទៅចាក់លើចានដែលមានដីភក់ ហើយសំអាតវាចេញ

ច. អ្វីដែលធ្លាប់កខ្វក់ ហើយប្រលាក់ ឥឡូវបានក្លាយទៅជាស្អាតហើយ នេះគឺដោយសារតែព្រះយេស៊ូវមិនបានធ្វើបាប ហើយទ្រង់បានសុគតជំនួសយើង!

### ៨. ខគម្ពីរចងចាំ

***ម៉ាថាយ ៤៖៧*** *ព្រះយេស៊ូវមានព្រះបន្ទូលទៅវាថា មានសេចក្ដីចែងទុកដូច្នេះទៀត «កុំឲ្យឯងល្បងព្រះអម្ចាស់ជាព្រះនៃឯងឡើយ»។*

### ៩. ហាត្ថកម្ម ផាត់ពណ៌រូបភាព «សេចក្ដីល្បួងទាំងបីចំពោះព្រះយេស៊ូវ»

សូមបោះពុម្ពទំព័រសំរាប់ឲ្យកុមារផាត់ពណ៌ (សូមមើលទំព័រខាងក្រោម)។

### ១០. ចំរៀង

*(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

### ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**
សូមអានគម្ពីរ លូកា ៤:៥-៨ សារឡើងវិញ។ សាតាំងបានល្បួងព្រះយេស៊ូវដោយផ្ដល់នូវ លោកីយ៍ទាំងមូលសម្រាប់ធ្វើជានគរឲ្យព្រះយេស៊ូវ។ តើលោកីយ៍ជាអំណោយរបស់សាតាំងឬ? មិនមែនទេ! លោកីយ៍គឺជាកម្មសិទ្ធរបស់ព្រះ។ ព្រះយេស៊ូវជ្រាបពីការនេះ ហើយទ្រង់មិនបានធ្លាក់ទៅក្នុងពាក្យកុហករបស់សាតាំងឡើយ។ ជំនួសឲ្យការជ្រើសរើសយកផ្លូវងាយស្រួល ព្រះយេស៊ូវបានរើស ផ្លូវដ៏លំបាកនៃឈើឆ្កាងទៅវិញ ពីព្រោះទ្រង់ ដឹងថាការនេះជាបំណងព្រះហឫទ័យរបស់ព្រះ។ បើសិនជាអ្នកប្រឈមជាមួយនឹងការល្បួងនៅថ្ងៃនេះ សូមនឹកចាំពីវិធីដែលព្រះគ្រីស្ទយកឈ្នះលើសេចក្ដីល្បួងនៅក្នុងទីរហោស្ថាន ហើយទូលសូមកំលាំងពីទ្រង់ដើម្បីឲ្យយើងអាចយកឈ្នះលើសេចក្ដីល្បួងទាំងនោះបានដែរ។

